## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

---

តុលាការខេត្តកណ្តាល
<u>សំណុំរឿងព្រហ្មទណ្ឌ</u>
លេខ ៣៥៦ អ.ក ចុះថ្ងៃទី ៣០
ខែ កញ្ញា ឆ្នាំ ១៩៩៥
<u>ជំនុំជំរះ</u>
លេខ ០៩ ភ ចុះថ្ងៃទី ២៣
ខែ មករា ឆ្នាំ ១៩៩៦
<u>សាលក្រម</u>
លេខ ០៩ ភ ចុះថ្ងៃទី ២៣
ខែ មករា ឆ្នាំ ១៩៩៦

---

### នាមនាមប្រជារាស្ត្រខ្មែរ
### តុលាការខេត្តកណ្តាល

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ បានបើកសវនាការជាសាធារណៈ នៅនាទីតុលាការខេត្តកណ្តាល នាថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៦ ដោយមានសមាសភាពដូចតទៅ :

**<u>ចៅក្រមជំនុំជំរះ</u>**

លោក [redacted] ប្រធានតុលាការខេត្តកណ្តាល

**<u>តំណាងអយ្យការ</u>**

លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការខេត្តកណ្តាល

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក [redacted] ក្រឡាបញ្ជីតុលាការខេត្តកណ្តាល

ដើម្បីជំនុំជំរះជនជាប់ចោទឈ្មោះ **ខ សល** ភេទប្រុស កើតឆ្នាំ ១៩៧៤ ជាតិខ្មែរ សញ្ជាតិកម្ពុជា កើតនៅសង្កាត់លេខ ៤ ក្រុងភ្នំពេញ កិតវប្បធម៌ថ្នាក់ទី ៨ សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិខ្មៅ ឃុំបឹងធំ ស្រុកអង្គស្នួល ខេត្តកណ្តាល របររកស៊ីនៅផ្ទះនៅលីវ ឪពុកឈ្មោះ **ខ អល** (រ) ម្តាយឈ្មោះ **ព រ** (រ) ទោសពីមុនគ្មាន ។

ត្រូវចាប់ខ្លួននៅថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៩៥ ពីបទ :**រំលោភលើសេចក្តីទុកចិត្ត និងធ្វើឱ្យខូចខាតដោយចេតនា** ប្រព្រឹត្តនៅភូមិខ្មៅ ឃុំបឹងធំ ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៩៥ និងថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ តាមមាត្រា ៤៦ និងមាត្រា ៥២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

តុលាការខេត្តកណ្តាលសម្រេចតាមដីកាលេខ : ៣២៦ ដកទម ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៩៥ ទទួលស្គាល់លោក [redacted] **ស៊ីថាន** ជាអ្នកការពារឱ្យជនជាប់ចោទឈ្មោះ **ខ សល** ។

ជនរងគ្រោះឈ្មោះ **ប ប** ភេទប្រុស អាយុ ២៣ឆ្នាំ ជាតិខ្មែរ ជានិស្សិតសកលវិទ្យាល័យភ្នំពេញ ទីលំនៅសព្វថ្ងៃភូមិខ្មៅ ឃុំបឹងធំ ស្រុកអង្គស្នួល ខេត្តកណ្តាល ។

តាមដីកាសន្និដ្ឋានស្ថាពរលេខ : ២៨៨ ដកសព/៩៦ ចុះថ្ងៃទី ៣០ ខែ វិច្ឆកា ឆ្នាំ ១៩៩៥ របស់ព្រះរាជអាជ្ញាអមតុលាការខេត្តកណ្តាល ។

តាមដីកាបញ្ជូនរឿងជំនុំជំរះលេខ : ២១៤ ដជរ/៩៥ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ របស់ចៅក្រមស៊ើបអង្កេតនៃតុលាការខេត្តកណ្តាល ។

តាមដីកាចាត់ចៅក្រមលេខ : ០៧ ដកច/៩៦ ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៩៦

*សាលក្រមនេះចូលជាស្ថាពរនៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ១៩៩៦ ចំពោះឈ្មោះ **ខ សល** ។*

*កណ្តាល.ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ១៩៩៦*

***ក្រឡាបញ្ជី***

[redacted]

***បានឃើញ***

***ប្រធានតុលាការខេត្តកណ្តាល***

[redacted]



Scanned with CamScanner

របស់តុលាការខេត្តកណ្តាល ។

## ការប្រព្រឹត្តិរបស់ជនជាប់មានដូចតទៅ :

កាលពីថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៩៥ ឈ្មោះ ខ សល បាជិះម៉ូតូជាមួយឈ្មោះ ម ម ទៅដល់សកលវិទ្យាល័យ ពេលនោះឈ្មោះ ខ សល បានខ្ចីម៉ូតូរបស់ឈ្មោះ ម ម ជិះទៅធ្វើការនៅនាយកដ្ឋានសុរិយោដី ហើយឈ្មោះ ម ម បាននិយាយឱ្យឈ្មោះ ខ សល មកទទួលខ្លួនវិញនៅម៉ោងបីរសៀល ។ លុះដល់ពេលកំណត់មិនឃើញឈ្មោះ ខ សល ទៅទទួល ឈ្មោះ ម ម ក៏ជិះម៉ូតូឌុបទៅផ្ទះ ។ ចំណែកឈ្មោះ ខ សល វិញបានយកម៉ូតូរបស់ឈ្មោះ ម ម ទៅលក់នៅផ្សារអូឬស្សីបានតម្លៃ ២៤០ដុល្លា (ពីររយសែសិបដុល្លាអាមេរិច) ហើយបានផ្តាំតាមឈ្មោះ អ សត និងឈ្មោះ ឈ គស ថាឱ្យប្រាប់ឈ្មោះ ម ម ផង ថាខ្លួនលក់ម៉ូតូនោះហើយ ។

លុះដល់ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ ឈ្មោះ ខ សល បានត្រឡប់ទៅផ្ទះវិញ ហើយពេលទៅដល់ផ្ទះបាននិយាយគំរាមកំហែងម្តាយរបស់ខ្លួនឱ្យទិញម៉ូតូមួយគ្រឿង និងយកលុយ ២០ម៉ឺន ឱ្យខ្លួនទើបសុខចិត្ត តែគាត់មិនព្រម ពេលនោះឈ្មោះ ខ សល បានបំផ្លិចបំផ្លាញទ្រព្យសម្បត្តិនៅក្នុងផ្ទះអស់ជាច្រើន ។

-បានឃើញរបាយការណ៍វិសាមញ្ញ ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៥ របស់នគរបាលស្រុកអង្គស្នួល ។

-បានឃើញកំណត់ហេតុដកហូតវត្ថុតាង ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៩៥ របស់នគរបាលស្រុកអង្គស្នួល ។

-បានឃើញលិខិតបញ្ជាក់អ្នករងគ្រោះ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៩៥ របស់មេឃុំបឹងធំ (ស្រុកអង្គស្នួល) ។

-បានឃើញរបាយការណ៍បូកសរុបការស៊ើបអង្កេតជាបឋម ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ១៩៩៥ របស់នគរបាលស្រុកអង្គស្នួល ។

## នាពេលសវនាការ

ជនជាប់ចោទឈ្មោះ ខ សល បានឆ្លើយថា : កាលពីថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៩៥ ខ្លួនបានជិះម៉ូតូជាមួយឈ្មោះ ម ម ទៅសកលវិទ្យាល័យភ្នំពេញ ហើយខ្លួនបានខ្ចីម៉ូតូរបស់ឈ្មោះ ម ម ជិះទៅធ្វើការនៅនាយកដ្ឋានសុរិយោដី ប៉ុន្តែខ្លួនមិនបានទៅកន្លែងធ្វើការទេ បែរជាយកម៉ូតូរបស់ឈ្មោះ ម ម ទៅលក់បានលុយ ២៤០ដុល្លា (ពីររយសែសិបដុល្លា) ។ ម៉ូតូរបស់ឈ្មោះ ម ម ម៉ាកដឺលុច៥០ សេរី៨០ ពណ៌ស្វៃ ។ លុះក្រោយមកខ្លួនចាយលុយអស់ ក៏បានត្រឡប់ទៅផ្ទះវិញនៅថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ ហើយបានឱ្យម្តាយទិញម៉ូតូឆាលីឱ្យមួយសំលុយ ២០ម៉ឺន ប៉ុន្តែគាត់មិនឱ្យខ្លួនក៏ច្រានតុចាយ បណ្តាលឱ្យបែកចុងទឹកកក០១ ថូផ្កា០១ ចាន០៤ និងក្រពឹតឆ្នាំង ០១ ព្រមទាំងបានគំរាមកំហែងម្តាយ និងវ៉ៃប្អូនទៀតផង ។

តាមការអានចម្លើយរបស់ឈ្មោះ ព រ ជាម្តាយបង្កើតរបស់ឈ្មោះ ខ សល ថា : តាំងពីតូចមកកូនរបស់ខ្លួនឈ្មោះ ខ សល មិនដែលស្តាប់តាមដំបូន្មានរបស់ខ្លួនទេ វាតែងតែបំផ្លាញខ្លួនគ្រប់ពេលវេលាជាហូរហែ ។ ក្រោយពេលចូលធ្វើការខ្លួនបានទិញម៉ូតូមួយគ្រឿងតម្លៃ ៣៤០ដុល្លា ឱ្យ ខ សល ជិះ ពេលជិះបានពីរខែ ខ សល ក៏លក់ចោលយកលុយចាយអស់ទើបចូលទៅផ្ទះវិញ ហើយពេលទៅដល់ផ្ទះវាតែងតែរករឿងហេតុគ្មានឈប់ឈរ ។ នៅថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៩៥ ឈ្មោះ ខ សល បានបោកយកម៉ូតូរបស់ឈ្មោះ ម ម ទៅលក់ចាយអស់ ហើយត្រឡប់ចូលទៅផ្ទះវិញ ហើយពេលទៅដល់ផ្ទះវាបានរករឿងបង្កហេតុ ដូចជា បោកចានឆ្នាំង ធុងទឹកកកជាដើម ។ ខ្លួនមិនទាមទារសំណងអ្វីទេ គឺសុំឱ្យតុលាការផ្តន្ទាទោសឈ្មោះ ខ សុល តាមច្បាប់ ។



Scanned with CamScanner

តាមការអានចម្លើយរបស់ឈ្មោះ ម ម ថា : កាលពីថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៩៥ ខ្លួនត្រូវឈ្មោះ ខ សល បោកយកម៉ូតូមួយគ្រឿងម៉ាកស៊ាំង៥០ សេរី៨០ ពណ៌ស្វៃ យកទៅលក់ ដោយឈ្មោះ ខ សល និយាយថា ខ្ចីខ្លួនយកទៅធ្វើការនៅនាយកដ្ឋានស៊ីវិលយោធី ហើយពេលម៉ោងបីរសៀលនឹងត្រឡប់មកយកខ្លួនវិញ ប៉ុន្តែដល់ពេលកំណត់ឈ្មោះ ខ សល មិនបានមកទេ ។ លុះបីថ្ងៃក្រោយមកឈ្មោះ ឈ. គ ស បានមកប្រាប់ខ្លួនថា ម៉ូតូខ្លួនត្រូវឈ្មោះ ខ សល លក់បាត់ហើយ ហើយបើចង់ដឹងទៅជួបវានៅកន្លែងធ្វើការ ។ លុះស្អែកឡើងខ្លួនក៏ទៅ ប៉ុន្តែមិនបានជួបឈ្មោះ ខ សល ឡើយ ខ្លួនពុំទាន់បានទទួលម៉ូតូយកមកវិញទេ ប៉ុន្តែខ្លួនមិនប្តឹងទាមទារអ្វីពីឈ្មោះ ខ សល ឡើយ គឺខ្លួនសុំឱ្យតុលាការផ្តន្ទាទោសឈ្មោះ ខ សល តាមច្បាប់ ។

តាមការអានកិច្ចសន្យាចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៩៥ របស់ឈ្មោះ ព រ ត្រូវជាម្តាយបង្កើត ឈ្មោះ ព ន ត្រូវជាម្តាយធំ ឈ្មោះ ម ម ត្រូវជាបងជីដូនមួយ សូមធ្វើកិច្ចសន្យាដូចខាងក្រោម :

១-យើងទាំងអស់គ្នាឈប់ទទួលស្គាល់ឈ្មោះ ខ សល ជាកូន ជាប្អូន ជាក្មួយចាប់ពីថ្ងៃនេះតទៅ ។

២-សូមប្រគល់ឈ្មោះ ខ សល ឱ្យសមត្ថកិច្ចធ្វើតាមច្បាប់ ដោយយើងទាំងអស់គ្នាគ្មានលទ្ធភាពនឹងអប់រំតទៅទៀតឡើយ ។

៣-យើងទាំងអស់គ្នា សុំសំណូមពរឱ្យក្រសួងមានសមត្ថកិច្ចធ្វើការផ្តន្ទាទោសជាទម្ងន់ ចំពោះឈ្មោះ ខ សល នេះ ព្រោះថា ខ្លាចក្រែងពេលត្រឡប់មកវិញវាធ្វើសកម្មភាពផ្សងផឹត មកលើយើងទាំងអស់គ្នា ។

ចំពោះប្រការទាំងបីខាងលើនេះ គឺសុទ្ធតែពាក្យពេចន៍របស់យើងខ្ញុំទាំងអស់គ្នា ប្រសិនបើយើងខ្ញុំមិនគោរពតាមប្រការបីខាងលើនេះទេ សូមទទួលខុសត្រូវចំពោះមុខច្បាប់ ។

តាមការអានរបាយការណ៍បូកសរុបស៊ើបអង្កេតជាបឋម ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ១៩៩៥ ថា :មានការបាត់បង់ម៉ូតូ សេ៥០ ពណ៌ស្វៃមួយគ្រឿង កាតគ្រីម៉ូតូមួយសន្លឹក ដែលជាកម្មសិទ្ធិរបស់ឈ្មោះ ម ម កាលពីថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រព្រឹត្តឡើងដោយឈ្មោះ ខ សល ។

តាមការអានចម្លើយរបស់សាក្សីឈ្មោះ អ សត ជាសាក្សីថា : នៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៩៥ វេលាម៉ោង ១៤:០០ ឈ្មោះ ខ សល មកប្រាប់ខ្លួន និងឈ្មោះ ឈ គស ថាវាលក់ម៉ូតូរបស់ឈ្មោះ ម ម ហើយឱ្យប្រាប់ឈ្មោះ ម ម ផង ។ កាលពីមុនមកឈ្មោះ ម ម មានម៉ូតូមួយគ្រឿងម៉ាក ឌីលុច៥០ ពណ៌ស្វៃ ។ ខ្លួនជាមិត្តភក្រជិតស្និទ្ធជាមួយឈ្មោះ ម ម ។

**តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានដូចតទៅ :**

-ជនជាប់ចោទជាមនុស្សមានស្មារតីទទួលខុសត្រូវពិតប្រាកដ

-អំពើរបស់ជនជាប់ចោទបានធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈសង្គម ។

-ជនជាប់ចោទបានសារភាពនូវអំពើរបស់ខ្លួនដែលបានប្រព្រឹត្តកន្លងមក

-ជនជាប់ចោទធ្លាប់បានរៀនសូត្រជ្រៅជ្រះគួរសមដែរ តែប្រព្រឹត្តអំពើដែលផ្ទុយពីច្បាប់ និងធ្វើបាបអ្នកមានគុណ ។

-មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ ខ សល ពីបទរំលោភលើសេចក្តីទុកចិត្ត និង ធ្វើឱ្យខូចខាតដោយចេតនា ប្រព្រឹត្តនៅភូមិខ្មៅ ឃុំបឹងធំ ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៩៥ និង ១៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ តាមមាត្រា ៤៦ និង ៥២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-តំណាងអយ្យការសុំឱ្យតុលាការផ្តន្ទាទោសជនល្មើសតាមច្បាប់ ។

**អង្គការពារជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានដូចតទៅ :**

កូនក្តីរបស់ខ្ញុំបាទមានកំហុសមែន ប៉ុន្តែសុំឱ្យតុលាការជួយបន្ធូរបន្ថយទោសផងព្រោះ :

-បានសារភាពនូវទោសកំហុសរបស់ខ្លួនចំពោះមុខតុលាការ

-នៅពេលចូលទៅដល់ផ្ទះបានសុំឱ្យម្តាយទិញម៉ូតូ និងសុំលុយពីម្តាយ

-នៅក្មេងបានរៀនសូត្រតិចតួច

-ខ្វះការអប់រំឱ្យបានជិតដល់

-ដោយយោលលើគោលការណ៍ថា ឪពុកម្តាយត្រូវតែចិញ្ចឹមកូន

-គ្មានចេតនានឹងបំផ្លាញទ្រព្យសម្បត្តិរបស់ម្តាយទេ គឺគ្រាន់តែប្រានកុបណ្តាលឱ្យខូចទ្រព្យសម្បត្តិទាំងនេះ ។

-ជនជាប់ចោទមានម្តាយចាស់ជរា និងប្អូនតូចៗបីនាក់ទៀត ដែលត្រូវជួយថែរក្សា ។

**សំដីចុងក្រោយរបស់ជនជាប់ចោទ :**

សុំឱ្យតុលាការជួយបន្ធូរបន្ថយទោសផង ពេលចេញទៅវិញឈប់ប្រព្រឹត្តអំពើបែបនេះទៀតហើយ ហើយខំកែខ្លួនឱ្យក្លាយទៅជាមនុស្សល្អ ។

-ក្រោយពីបានស្តាប់ចំលើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនរងគ្រោះ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយចុងក្រោយរបស់ជនជាប់ចោទ

**តុលាការ**

ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់

**យល់ឃើញថា**

-អវត្តមានរបស់ជនរងគ្រោះ និងសាក្សី ពុំប៉ះពាល់ដល់នីតិវិធីនៃការជំនុំជំរះឡើយ ។

-ជនជាប់ចោទឈ្មោះ ខ សល ជានីតិជនធ្លាប់បានរៀនសូត្រចេះដឹងបង្គួរ អាចត្រិះរិះពិចារណា និងយល់ដឹងច្បាស់ពីអំពើ និងបច្ច័យដែលកើតឡើងពីអំពើរបស់ខ្លួន ដែលត្រូវទទួលខុសត្រូវទាំងស្រុងផ្នែកព្រហ្មទណ្ឌលើអំពើដែលខ្លួនប្រព្រឹត្ត ។

-ជនរងគ្រោះពិតជាបានប្រគល់ម៉ូតូដែលជាទ្រព្យសម្បត្តិរបស់ខ្លួន ឱ្យទៅជនជាប់ចោទយកទៅជិះ តែផ្ទុយទៅវិញជននេះបានយកម៉ូតូដែលជារបស់អ្នកដទៃ យកទៅលក់ដើម្បីយកលុយមកប្រើប្រាស់ប្រយោជន៍ផ្ទាល់ខ្លួនទៅវិញ ហើយជនជាប់ចោទខ្លួនឯងក៏បានសារភាពនៅចំណុចនេះដែរ ។

-ជនជាប់ចោទពិតជាបានដឹងថា ម៉ូតូម៉ាកជីលុច៥០ សេរី៨០ ពណ៌ស្វៃ ពិតជាកម្មសិទ្ធិរបស់ឈ្មោះ ម ម តែឈ្មោះនេះ នៅតែយកទ្រព្យសម្បត្តិដែលអ្នកដទៃប្រគល់ឱ្យខ្លួនមួយរយៈប៉ុណ្ណោះទៅលក់ ចំណុចនេះបង្ហាញពីចេតនាទុច្ចរិតរបស់ជនជាប់ចោទ ។

-ម៉ូតូជនរងគ្រោះត្រូវបាត់បង់ដោយអំពើរបស់ជនជាប់ចោទ កាលពីថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៩៥ ។



Scanned with CamScanner

-ការផ្តល់ដំណឹងតាមរយៈសាក្សីឈ្មោះ អ សគ ទៅឱ្យជនរងគ្រោះបានដឹងពីទ្រព្យសម្បត្តិរបស់គេនោះ ពុំអាចចាត់ទុកថាជនជាប់ចោទមានចិត្តស្មោះត្រង់ និង សុចរិតឡើយ ។

-ពិតមែនតែជនជាប់ចោទបានប្រព្រឹត្តបទល្មើសនៅទីក្រុងភ្នំពេញ តែជននេះមានទីលំនៅ ហើយត្រូវបានចាប់ខ្លួននៅស្រុកអង្គស្នួល ខេត្តកណ្តាល ដូចនេះតុលាការខេត្តកណ្តាលមានសមត្ថកិច្ចជំនុំជំរះ តាមការចោទប្រកាន់របស់តំណាងអយ្យការបាន ។

-សេចក្តីចោទប្រកាន់របស់តំណាងអយ្យការ មានសំអាងគ្រប់គ្រាន់តាមផ្លូវច្បាប់ ។

-មានភស្តុតាង និងពិរុទ្ធគ្រប់គ្រាន់លើឈ្មោះ ខ សល ថាពិតជាបានប្រព្រឹត្ត បទរំលោភលើសេចក្តីទុកចិត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៩៥ បទល្មើសដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-មាត្រា ៤៦ ចែងថា :

ជនណាដែលតែបន្លំ រឺបំបាត់ឱ្យខូចប្រយោជន៍ដល់ម្ចាស់កម្មសិទ្ធិ ម្ចាស់ទីកន្លែង ឬអ្នកកាន់កាប់ទ្រព្យសម្បត្តិប្រាក់កាក់ទំនិញ ឬគ្រប់ឯកសារដែលមាន ឬ ដែលចែងអំពីកាតព្វកិច្ច ឬការដោះបន្ទុកដែលគេប្រគល់ឱ្យមកខ្លួនក្នុងលក្ខណៈ ជាការជួល ការដាក់តំកល់ទុក ជាអាណត្តិ ជាការឱ្យខ្ចីប្រើ ឬដើម្បីការងារមានបៀវត្សដែលត្រូវប្រគល់ឱ្យគេវិញ ឬធ្វើជាតំណាង ឬសម្រាប់ប្រើប្រាស់ ឬជាមុខការមានកំណត់ ត្រូវមានទោសមជ្ឈិមពីបទ រំលោភសេចក្តីទុកចិត្ត ហើយត្រូវផ្តន្ទាទោសដាក់គុកពី ០១ ទៅ ០៥ឆ្នាំ ។

-ចម្លើយរបស់ជនជាប់ចោទដែលឆ្លើយថា ខ្លួនពុំមានចេតនាធ្វើឱ្យខូចខាតទ្រព្យសម្បត្តិរបស់ម្តាយខ្លួនទេជាចម្លើយដែលតុលាការពុំអាចជឿបានឡើយ ដោយហេតុថាឈ្មោះនេះ តែងតែប្រព្រឹត្តអំពើបែបនេះជាប្រចាំ ហើយនៅថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ ទ្រព្យសម្បត្តិដែលខូចខាត មានធុងទឹកកកមួយ ចានបួន ថូផ្កាមួយ ឆ្នាំមួយ ពុំមានតុល្យភាពនឹងអំពើរបស់ជននេះ គ្រាន់តែបានប្រានតុថ្លលឡើយ ។

-ពិតមែនតែឈ្មោះ ខ សល ជាកូនបង្កើតរបស់ជនរងគ្រោះ ប៉ុន្តែឈ្មោះនេះជានីតិជនមានអាយុ ២១ឆ្នាំជាជនផុតពីបន្ទុកជនរងគ្រោះ ដូចនេះអំពើបំផ្លិចបំផ្លាញទ្រព្យ ដែលមិនមែនស្ថិតនៅកម្មសិទ្ធិរបស់ខ្លួនត្រូវចាត់ទុកជាអំពើខុសច្បាប់ព្រហ្មទណ្ឌដែលបានហាមឃាត់ ។

-សកម្មភាពជនជាប់ចោទ ដែលបានធ្វើឱ្យខូចខាតទ្រព្យសម្បត្តិដែលមិនជារបស់ខ្លួន បង្ហាញឱ្យឃើញពីឆន្ទៈរបស់ជននេះថា ពិតជាមានចេតនានឹងធ្វើឱ្យខូចខាតប្រាកដច្បាស់ ។

-ទ្រព្យសម្បត្តិដែលខូចខាតមានតម្លៃតិចតួច ដែលតុលាការនឹងពិចារណាជាមូលដ្ឋានក្នុងការកំរិតទណ្ឌកម្ម ។

-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់បញ្ជាក់ថាឈ្មោះ ខ សល ពិតជាបានប្រព្រឹត្តបទ ធ្វើឱ្យខូចខាតដោយចេតនា នៅចំណុចភូមិខ្ចៅ ឃុំបឹងធំ ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ ប្រាកដមែន ។

-បទល្មើសដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៥២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

-មាត្រា ៥២ ចែងថា :

ជនណាដែលធ្វើឱ្យខូចខាត ឬ ប៉ុនប៉ងធ្វើឱ្យខូចខាតដោយចេតនា នូវទ្រព្យសម្បត្តិអ្នកដទៃត្រូវមានទោសមជ្ឈិមពីបទ ធ្វើឱ្យខូចខាតដោយចេតនា ហើយផ្តន្ទាទោសដាក់គុកពី ០១ឆ្នាំ ទៅ ០៣ឆ្នាំ ។ បើការខូចខាត



Scanned with CamScanner

នោះមានលក្ខណៈស្រាល ឬ ទ្រព្យសម្បត្តិនេះមានតម្លៃតិចតួច ទោសដាក់គុកត្រូវបញ្ចុះមកត្រឹម ០២ខែ ទៅ ០១ឆ្នាំ ។ ការធ្វើឱ្យខូចសម្បត្តិវប្បធម៌ ដែលជាបេតិកភ័ណ្ឌជាតិកម្ពុជា ត្រូវមានទោសតាមមាត្រា ៤៤ ។

-ជនជាប់ចោទនៅវ័យក្មេងនៅឡើយ ដូចនេះគួរតប្បីតុលាការលើកយកមាត្រា ៦៨ មកអនុវត្ត ។

-បណ្ដឹងរបស់ជនរងគ្រោះឈ្មោះ ព ៖ បញ្ហាកាត់កាលកូនឈ្មោះ ខ សល ពុំស្ថិតក្នុងសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌឡើយ ដូចនេះតុលាការពុំលើកយកមកសម្រេចសេចក្ដីនាពេលនេះឡើយ ។

-វត្ថុតាងមាន ចាន០៤, ឆ្នាំ ០១, ធុងទឹកកក០១, ថូផ្កា០១ ពុំមានតម្លៃប្រើប្រាស់ទៀតឡើយ ។

-ជនរងគ្រោះពុំទាមទារសំណងអ្វីទេ ដូចនេះតុលាការពុំតប្បីលើកយកមកពិចារណាឡើយ ។

## ហេតុដូច្នេះសំរេច

១-ផ្ដន្ទាទោស :

ឈ្មោះ ខ សល ភេទប្រុស កើតឆ្នាំ ១៩៧៤ កំណត់ដាក់ពន្ធនាគារសរុបចំនួន ០១ឆ្នាំ គិតពីថ្ងៃឃុំខ្លួនថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ពីបទ **រំលោភលើសេចក្ដីទុកចិត្ត** ប្រព្រឹត្តនៅភ្នំពេញ កាលពីថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៩៥ និងបទ **ធ្វើឱ្យខូចខាតដោយចេតនា** ប្រព្រឹត្តនៅចំណុចភូមិខ្មៅ ឃុំបឹងធំ ស្រុកអង្គស្នួល ខេត្តកណ្ដាល កាលពីថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ ។ តាមបញ្ញត្តិ មាត្រា ៤៦, ៥២ និង ៦៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

២-វត្ថុតាងមាន :

-ធុងទឹកពណ៌ក្រហមមួយ

-ចានបែកបួន

-ឆ្នាំងក្រពិតមួយ

-ថូផ្កាបែកមួយ

-ឫស្សី

ត្រូវបំផ្លាញចោល ។

៣-សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ កំបាំងមុខជនរងគ្រោះ បើកផ្លូវប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ចៅក្រមជំនុំជំរះ**

[redacted]

---

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីអនុវត្តសាលក្រមឱ្យសម្រេចតាមសាលក្រមនេះ និង អាជ្ញាធរគ្រប់តំណែងគ្រប់ជាន់ថ្នាក់ជួយផ្ដល់កម្លាំង ដើម្បីសម្រេចការអនុវត្តនេះ បើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

*កណ្ដាល, ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ១៩៩៦*

**ប្រធានតុលាការខេត្តកណ្ដាល**

[redacted]

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner